កាលបរិច្ឆេទៈ ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨

# មេរៀនដាំណាំនោងនាល

## វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំនោងនាល

### ក) ការរៀបចំដី

១-ភ្ជួររាស់និងហាលដីរយៈពេល១ថ្ងៃទៅ១៥ថ្ងៃ

២-ភ្ជួរដី២ឬ៣ដងបន្ថែមទៀតដើម្បីធ្វើឱ្យស្មៅងាប់ សម្លាប់សត្វស្អិតចង្រៃ និងធ្វើឱ្យដីធូរមានអុកស៊ីសែនផងដែរ។

### ខ) ការរៀបចំរងនិងរណ្តៅដាំ

១-យើងអាចលើករងទទឹងប្រវែងពី៥០ទៅ៦០សង់ទីម៉ែត្រ(៥-៦តឹក) បណ្តោយរងយោងទៅតាមទំហំដី រីឯកំពស់យកប្រវែងពី១០ទៅ១៥សង់ទីម៉ែត្រ(១តឹកទៅ១តឹកកន្លះ)នៅក្នុងរដូវប្រាំង ចំណែកឯនៅក្នុងរដូវវស្សាយកប្រវែងពី១៥ទៅ២០សង់ទីម៉ែត្រ(១តឹកកន្លះទៅ២តឹក)។ បន្ទាប់ពីនោះកាប់ចង្អូរតាមបណ្តោយរង។

២-ជីករណ្តៅក្នុងជម្រៅពី២០ទៅ៣០សង់ទីម៉ែត្រ(២-៣តឹក) រីឯជ្រុងរណ្តៅនីមួយៗយកប្រវែងពី២ទៅ៣តឹក ហើយចន្លោះពីរណ្តៅ១ទៅរណ្តៅ១យកប្រវែង១ម៉ែត្រទៅ២ម៉ែត្រ។

៣-ដាក់ជីធម្មជាតិច្របល់ជាមួយដីដែលនៅបាតរណ្ដៅ បន្ទាប់មកលុបដីទៅក្នុងរណ្ដៅឱ្យមានផ្ទៃរាបស្មើ។

## គ) ការដាំដុះននោងនាល

១-យកគ្រាប់ពូជមកត្រាំទឹករយៈពេល១យប់បន្ទាប់មកផ្អាប់១យប់ទៀត

២-ដាក់គ្រាប់ពូជននោងនាលចំនួន៣គ្រាប់សម្រាប់១រណ្ដៅ ហើយកប់វាក្នុងជម្រៅ១ថ្នាំងដៃ។

៣-បន្ទាប់ពីដាំរួច ត្រូវស្រោចទឹកវាឱ្យជោគ។

## ឃ) ការធ្វើទ្រើង

នៅពេលននោងលូតលាស់បានបន្តិច យើងត្រូវធ្វើទ្រើងឱ្យវាវារឡើង ដោយយកទទឹងប្រវែង២ទៅ៣ម៉ែត្រ បណ្ដោយទៅតាមលទ្ធភាព រីឯកំពស់យកប្រវែង១ម៉ែត្រកន្លះ។

## ង) ការថែទាំននោងនាល

១-ដកស្មៅ

២-ជ្រុំជើង

៣-ដាក់ជីធម្មជាតិ

៤-ស្រោចទឹក២ដងក្នុង១ថ្ងៃនៅពេលព្រឹកនិងពេលល្ងាច

៥-ឃ្លាំមើលសត្វល្អិត។

កាលបរិច្ឆេទៈ ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨

## ច) ការប្រមូលផល

នៅពេលននោងមានអាយុ៤០ទៅ៤៥ថ្ងៃ យើងអាចប្រមូលផលបាន៕

**សូមអរគុណ**

កាលបរិច្ឆេទៈ ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨

# មេរៀនដំណាំជីតាំងអោ

## វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំជីតាំងអោ

### ក) ការរៀបចំដី

១-ភ្ជួររាស់និងហាលដីរយៈពេល១ថ្ងៃទៅ១៥ថ្ងៃ

២-ភ្ជួរដី២ឬ៣ដងបន្ថែមទៀតដើម្បីធ្វើឱ្យស្មៅងាប់ សម្លាប់សត្វស្អិតចង្រៃ និងធ្វើឱ្យដីធូរមានអុកស៊ីសែនផងដែរ។

### ខ) ការរៀបចំរង

១-យើងអាចលើករងទទឹងប្រវែង១ម៉ែត្រ បណ្តោយយោងទៅតាមទំហំដី រីឯកំពស់យកប្រវែងពី១០ទៅ១៥សង់ទីម៉ែត្រ(១តឹកទៅ១តឹកន្លះ) នៅក្នុងរដូវប្រាំងចំណែកឯនៅក្នុងរដូវវស្សាយកប្រវែងពី២០ទៅ៣០សង់ទីម៉ែត្រ (២ទៅ៣តឹក)។

២-ប្រើជីធម្មជាតិសម្រាប់ដាក់នៅបាតរង។

### គ) ការដាំតាំអោ

១-យកគ្រាប់ពូជមកត្រាំទឹករយៈពេល១យប់បន្ទាប់មកផ្អាប់១យប់ទៀត

២-យកដីខ្សាច់៤ភាគ លាយជាមួយគ្រាប់តាំអោ បន្ទាប់មកយកគ្រាប់សាបឱ្យស្មើដៃនៅក្នុងរង។

៣-យកកំទេចចំបើងគ្របលើរងដើម្បីការពារគ្រាប់ឃ្លាតចេញក្រៅ។

៤-ធ្វើដំបូលគ្របលើរង(គ្រាប់មិនទាន់ដុះនៅឡើយ) ប្រសិនបើអាច ប៉ុន្តែនៅពេលដែលគ្រាប់តាំអោចេញពន្លកត្រូវដកដំបូលចេញ។

## ឃ) ការថែទាំ

១-នៅពេលកូនតាំអោមានអាយុពី១០ទៅ១៥ថ្ងៃត្រូវដកស្មៅជ្រុំជើង។

២-ប្រើទឹកអ៊ុអឹមពី២០ទៅ៣០សេសេ លាយជាមួយទឹក១៥លីត្រ ហើយកូរវាផងមុនពេលបាញ់ទៅលើដំណាំ។

៣-ឃ្លាំមើលសត្វល្អិតចង្រៃជាប្រចាំ។

៤-ស្រោចទឹក២ដងក្នុង១ថ្ងៃនៅពេលព្រឹកនិងពេលល្ងាច។

## ង) ការប្រមូលផល

នៅពេលដំណាំតាំអោមានអាយុ៣០ថ្ងៃទៅ៣៥ថ្ងៃ យើងអាចប្រមូលផលបាន៕

**សូមអរគុណ**